**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខនស/រកត/០៩៩៥ /៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ មានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេង សាវឿន** អនុប្រធានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លូ រ៉ាមីន** អគ្គលេខាធិការ នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធាន

www.pheakdeylaw.com

៣- ឯកឧត្តម អ៊ឹង តំរូន   រដ្ឋលេខាធិការក្រសួងសុខាភិបាល   សមាជិក

៤- ឯកឧត្តម ម៉ិន· សម   រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ   សមាជិក

៥- ឯកឧត្តម ខៀវ មុត   រដ្ឋលេខាធិការក្រសួងបរិស្ថាន   សមាជិក

៦- ឯកឧត្តម សាត សាវី   អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល   សមាជិក

៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ   អនុរដ្ឋលេខាធិការក្រសួងការពារជាតិ   សមាជិក

៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក នេត សាវឿន   អគ្គស្នងការរងនគរបាលជាតិ   សមាជិក

៩- ឯកឧត្តម កង ហ៊ាង   អភិបាលខេត្តកំពង់ស្ពឺ   សមាជិក

១០- ឯកឧត្តម ឧត្តមសេនីយ៍ទោ ម៉ុក ដារ៉ា   អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ និងនាយកមន្ទីរប្រឆាំងគ្រឿងញៀន   សមាជិក

១១- លោក គីម សោភ័ណ   ចៅក្រម ក្រសួងយុត្តិធម៌   សមាជិក

១២- លោកឧត្តមសេនីយ៍ត្រី ទូច ណារ៉ុថ   ស្នងការនគរបាលរាជធានីភ្នំពេញ   សមាជិក

១៣- លោកវរៈសេនីយ៍ឯក កែវ ពិសី   ស្នងការនគរបាលខេត្តកំពង់ស្ពឺ   សមាជិក

១៤- លោក មាស វិរិទ្ធ   ប្រធានមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន   សមាជិក

១៥- លោក ឃុត សុភាង   ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ស្ពឺ   សមាជិក

១៦- លោក ដួង ស៊ុនណារ៉ា   ប្រធានស្ដីទី នាយកដ្ឋានអនុវត្តច្បាប់   សមាជិក

**ប្រការ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តកំពង់ស្ពឺ សាលាក្រុងភ្នំពេញ និងសាមីខ្លួនមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com